# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ឧត្តមសេនីយ៍ហ៊ីង-ប៊ុនហៀងជាអង្គរក្ស ផ្ទាល់របស់នាយករដ្ឋមន្ត្រីខ្មែរបានត្រូវតែងតាំងជា ឧត្តមប្រឹក្សាអមថេរសភាសង្ឃ ។

web site : www.hoksavann.org

ថ្ងៃទី១៣ វិច្ឆិកា ២០០៦

ឧត្តមសេនីយ៍ហ៊ីង-ប៊ុនហៀងជានាយកប្រដាប់អាវុធការពារប្រមុខរដ្ឋាភិបាល គឺជាអង្គរក្សផ្ទាល់របស់នាយករដ្ឋមន្ត្រីខ្មែរ បានត្រូវតែងតាំងជាឧត្តមទីប្រឹក្សាអមថេរសភាសង្ឃព្រះពុទ្ធសាសនា តាមអនុក្រឹត្យចុះថ្ងៃ៦កញ្ញាឆ្នាំ២០០៦ ។ នេះជាដំណឹងតាមសារពត៌មាន The Cambodia Daily ។ កាលពីប៉ុន្មានឆ្នាំមុននេះ មានទស្សនាវដ្ដីមួយឈ្មោះទស្សនាវដ្ដីសេដ្ឋកិច្ចចុងបូព៌ា (Far Eastern Economic Review) បានផ្សាយថា ឧត្តមសេនីយ៍ហ៊ីង-ប៊ុនហៀងមានឈ្មោះមិនល្អ ក្រោយរដ្ឋប្រហារឆ្នាំ១៩៩៧ មានការទាក់ទងនឹងអំពើឃាតកម្មសមាជិកគណបក្សហ៊្វុនស៊ិនប៉ិច ។ ការតែងតាំងនេះមានប្រតិកម្មយ៉ាងខ្លាំងអំពីគណបក្សជំទាស់និងអង្គការសិទ្ធិមនុស្សនានាក្នុងស្រុក ដោយយល់ថាការតែងតាំងមន្ត្រីអ្នកមានអាវុធ ឲ្យសំរេចកាត់ក្ដីព្រះសង្ឃបែបនេះ មិនល្អសំរាប់ព្រះពុទ្ធសាសនាឡើយ ។

ចំពោះយើងវិញក៏យល់ស្របតាមប្រតិកម្មរបស់អង្គការសិទ្ធិមនុស្សនានា គឺការតែងតាំងអ្នកមានអំណាចក្នុងផ្លូវអាណាចក្រ ឲ្យមកកាត់ក្ដីរឿងព្រះសង្ឃក្នុងផ្លូវពុទ្ធចក្រ ជាការខុសឆ្គងខ្លាំងណាស់ក្នុងរាជាណាចក្រកម្ពុជា ដែលទុកព្រះសង្ឃជាទីសក្ការៈបូជា ។ តាមពិតតាំងពីបូរាណមក រចនាសម្ព័ន្ធរបបគ្រប់គ្រងព្រះសង្ឃផ្សេងដាច់ដោយឡែក ពីរបបគ្រប់គ្រងខាងផ្លូវអាណាចក្រ ។ ពីដើមមក ក៏មានបង្កើតថេរសភាសង្ឃ សំរាប់កាត់សេចក្ដីជាចុងក្រោយ ចំពោះព្រះសង្ឃដែលមានកំហុសក្នុងព្រះវិន័យ បន្ទាប់ពីព្រះវិន័យធម៌សាលាអនុគណ និងសាលាមេគណតាមខេត្តកាត់សេចក្ដីមិនដាច់ស្រេច មានលក្ខណៈជាតុលាការជាន់ខ្ពស់របស់ព្រះសង្ឃ ។ ឯសមាសភាពនៃសមាជិកថេរសភាសង្ឃ ត្រូវបានជ្រើសរើសពីព្រះសង្ឃរាជាគណៈ ដែល

ពុំមានគ្រហស្ថជាសមាជិកឡើយ ទោះបីធ្វើជាទីប្រឹក្សាក៏ដោយ ។

ការតែងតាំងឧត្តមសេនីយ៍ដែលកាន់កាំភ្លើង ហើយជាអង្គរក្សរបស់នាយករដ្ឋមន្ត្រីផ្ទាល់ ឲ្យធ្វើជាទីប្រឹក្សាជាន់ខ្ពស់របស់តុលាការកាត់ទោសព្រះសង្ឃបែបនេះ ធ្វើឲ្យគេមើលឃើញថា រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ដែលមន្ត្រីភាគច្រើនជារបស់គណបក្សប្រជាជនកម្ពុជា មិនត្រឹមតែប្រើឥទ្ធិពលរបស់ខ្លួនទៅលើស្ថាប័នជាតិក្នុងផ្លូវអាណាចក្រប៉ុណ្ណោះទេ ឥឡូវនេះបានប្រើឥទ្ធិពលមកលើស្ថាប័នព្រះពុទ្ធសាសនាទៀត ។ បានសេចក្តីថា បើព្រះសង្ឃអង្គណាដែលមិនដើរតាមមាគ៌ារបស់គណបក្សប្រជាជន ឬមានការប្រឆាំង, ឧត្តមសេនីយ៍ជាទីប្រឹក្សានោះអាចរកលេសចោទកំហុស បង្គាប់ឲ្យថេរសភាសង្ឃកាត់ទោសព្រះសង្ឃអង្គនោះ ។ នេះជាការតែងតាំងខុសទម្លាប់ ដែលចាត់ថា អ្នកនយោបាយបានចូលមកជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ព្រះសង្ឃ ដែលជាស្ថាប័នស្ងប់រម្ងាប់ នេះជាទង្វើគួរឲ្យស្តាយចំពោះប្រទេសកម្ពុជា ដែលគោរពព្រះពុទ្ធសាសនា ស្ទើរតែមួយរយភាគរយ ហើយមានចែងក្នុងរដ្ឋធម្មនុញ្ញថា ជាសាសនារបស់រដ្ឋថែមទៀត ។ រាជរដ្ឋាភិបាលប្រទេសថៃនិងប្រទេសភូមា ដែលសព្វថ្ងៃជារបបយោធានិយមផង ក៏គេមិនអនុវត្តដូចរាជរដ្ឋាភិបាលខ្មែរ ដែលយកអំណាចផ្លូវអាណាចក្រ មកគ្របសង្កត់លើផ្លូវពុទ្ធចក្រឡើយ ។ តាមច្បាប់កុម្មុយនិស្តសេរីនិយម ដែលពុំមែនជាច្បាប់កុម្មុយនិស្តខ្មែរក្រហម អ្វីៗឲ្យមានប៉ុន្តែនៅក្រោមការត្រួតត្រានិងឃ្លាំមើលរបស់បក្សកុម្មុយនិស្ត ដូចស្ថាប័នសាសនាជាដើម ។ ការតែងតាំងរបៀបនេះ ជាការរឹតបន្តឹងខាងផ្លូវព្រះពុទ្ធសាសនា ហើយជាការឃ្លាំមើលឲ្យបានដិតដល់គ្រប់សកម្មភាពរបស់ព្រះសង្ឃ ។

យើងសូមស្នើឲ្យដកឧត្តមសេនីយ៍ ដែលតែងតាំងឲ្យធ្វើជាទីប្រឹក្សាជាន់ខ្ពស់របស់ថេរសភាសង្ឃនេះចេញ ទុកឲ្យព្រះសង្ឃបំពេញកិច្ចការដោយឯករាជ្យស្របតាមធម៌វិន័យ ។ ការតែងតាំងនេះជាការខុសឆ្គងខ្លាំងណាស់ នាំឲ្យមតិអ្នកកាន់ព្រះពុទ្ធសាសនាថ្កោលទោស ជាការខូចតម្លៃរាជរដ្ឋាភិបាលវិញទេ ។ ជាពិសេសខ្មាស់ប្រទេសជិតខាងមានប្រទេសថៃជាដើម ដែលគេគោរពព្រះពុទ្ធសាសនា សើចចំអកថា រាជរដ្ឋាភិបាលខ្មែរតែងតាំងអ្នកកាន់កាំភ្លើងឲ្យចូលរួមកាត់ទោសព្រះសង្ឃបែបនេះ គ្មានទំនងទាល់តែសោះ ពិតជាមានគោលដៅនយោបាយ ក្នុងការត្រួតត្រាលើព្រះសង្ឃ ដែលតាមធម្មតាជាស្ថាប័នដាច់ដោយឡែក ដែលមានព្រះវិន័យរបស់ព្រះពុទ្ធសាសនាជាច្បាប់កំពូលរបស់ព្រះសង្ឃ មិនត្រូវយកអំណាចរដ្ឋមកគ្របសង្កត់លើព្រះវិន័យរបស់ព្រះសង្ឃឡើយ ។៚

❀ ❀

❀